សេចក្តីថ្លែងការណ៍ស្តីពី ការអភិវឌ្ឍន៍វិស័យកសិកម្ម
វេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា
ថ្ងៃទី ១៩_២០ ខែ មិថុនា ឆ្នាំ ២០០៧

ដោយឯកឧត្តម បណ្ឌិត ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

~~~~~~~~

- *សូមគោរពសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ តំណាងដ៏ខ្ពង់ខ្ពស់របស់ប្រទេស និងភ្នាក់ងារជាដៃគូ*
- *សមាជិក សមាជិកា នៃអង្គវេទិកា ជាទីមេត្រី*

ថ្ងៃនេះ ខ្ញុំមានកិត្តិយសដើម្បីធ្វើនូវសេចក្តីថ្លែងការណ៍ដោយសង្ខេបពីគោលនយោបាយ យុទ្ធសាស្ត្រ យន្តការ និង សមិទ្ធផលដែលសំរេចបានក្នុងដំណើរការអភិវឌ្ឍន៍វិស័យកសិកម្មជារួម ។

វិស័យកសិកម្មជាវិស័យដែលមានទំនាក់ទំនងជាលក្ខណៈអន្តរវិស័យ និង ដើរតួសំខាន់ៗជាចម្បង (1)- ធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅជនបទ ដែលមានប្រមាណ ៨០% នៃប្រជាជនកម្ពុជា (2)- ដើរតួជាមូលដ្ឋានសំខាន់ក្នុងការរួមចំណែកដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ (3)- ទ្រទ្រង់ដល់មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចកម្ពុជា (4)- រក្សានូវបរិស្ថានធម្មជាតិ និង (5)- កសិ-ទេសចរណ៍ ។

តាមរយៈនៃទស្សនៈវិស័យអភិវឌ្ឍន៍វិស័យកសិកម្ម ដែលឈរលើមូលដ្ឋាននៃរបៀបវារៈគោលនយោបាយជាតិ និងយុទ្ធសាស្ត្រចតុកោណ បន្ថែមលើរចនាសម្ព័ន្ធ និង យន្តការមានស្រាប់របស់រដ្ឋាភិបាល រាជរដ្ឋាភិបាលបានបង្កើតឡើងនូវក្រុមការងារបច្ចេកទេស ដែលមានអស់លោកជាតំណាងប្រទេសផ្តល់ជំនួយចូលរួម ក្នុងកម្មវត្ថុនៃការជំរុញការអភិវឌ្ឍវិស័យកសិកម្មតាមយន្តការរួមរវាងរដ្ឋាភិបាល និង ប្រទេសផ្តល់ជំនួយ ។ យន្តការនេះបានកំណត់ច្បាស់នូវភារកិច្ច ចម្បងនៃក្រុមការងារ ពីការកៀងគរថវិកាសម្រាប់ការអភិវឌ្ឍកម្មវិធី និងគំរោងអភិវឌ្ឍន៍កសិកម្ម ។

នៅរាល់កិច្ចប្រជុំរវាងរាជរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយ ដែលពេលនេះបានឱ្យឈ្មោះថា វេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍ កម្ពុជា (CDCF) នេះ តែងតែឯកភាពគ្នាពី JMI សំរាប់រួមគ្នាអនុវត្ត ។ ជារួម JMI ដែលបានកំណត់ដោយកិច្ចប្រជុំ CG លើកមុន ត្រូវបានរាជរដ្ឋាភិបាល និងដៃគូប្រទេសផ្តល់ជំនួយបានសហការគ្នាសំរេចបានគួរឱ្យកត់សម្គាល់ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ថវិកាដែលកៀងគរបានសម្រាប់ការអភិវឌ្ឍសកម្មភាពដែលបានឯកភាពគ្នាហើយនោះនៅមានកម្រិត ដែលធ្វើឱ្យការអនុវត្តសកម្មភាពមួយចំនួនត្រូវបានយឺតជាងការគ្រោងទុក តែសកម្មភាពទាំងនោះនៅតែត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជំរុញអនុវត្តដោយមិនបោះបង់ចោល តាមរយៈការកៀងគរបន្ថែមនូវថវិកាគ្រប់ប្រភពរួមទាំងផ្នែកឯកជនផងដែរ ។

ជាក់ស្តែងក្រុមការងារកសិកម្ម និងទឹក ដែលមាន AusAID ចូលរួមជាដៃគូបានសម្រេចនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម និងទឹក ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយមបានអនុម័តតាំងពីខែ មិនា ២០០៧ កន្លងទៅនេះ ។ យុទ្ធសាស្ត្រនេះនឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ដាក់ចេញនូវសកម្មភាពអនុវត្តជាក់ស្តែង ព្រោះយើងមិនផលិតឯកសារសម្រាប់តាំងលំអទេ ។ សមិទ្ធផលពិស្តាររបស់ក្រុមការងារកសិកម្ម និង ទឹក
~~~~~~~~

និងត្រូវបកស្រាយបន្ថែមទៀតនេះដោយឯកឧត្តម **វេង សុខុន** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម និង ជាសហប្រធាន ។

ក្នុងទិសដៅអភិវឌ្ឍន៍ផលិតកម្មកសិកម្ម និងក្នុងគោលនយោបាយផ្នែកឯកជនជាដៃគូ ដីសម្បទានសេដ្ឋកិច្ចត្រូវបានផ្ដល់ជូនដល់វិនិយោគិនតាមបញ្ញត្តិនៃច្បាប់ស្ដីពីវិនិយោគ និងអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច ។ សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្ដល់ក្នុងកម្មវត្ថុនៃការបង្កើនផលិតភាព និងគុណភាពផលិតផលដោយធានាបាននូវសុខភាពបរិស្ថានតាមរយៈការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច សង្គម និងបរិស្ថាន ។

ការផ្ដល់សម្បទានដីសេដ្ឋកិច្ច ត្រូវបានផ្អែកលើលទ្ធផលនៃការចុះពិនិត្យជាក់ស្ដែងដល់មូលដ្ឋាន តាមរយៈយន្តការក្រុមការងារអន្តរជំនាញ និងពិគ្រោះយោបល់ជាមួយមូលដ្ឋាន (អាជ្ញាធរ និងប្រជាពលរដ្ឋ) និងយោបល់របស់លេខាធិការដ្ឋានបច្ចេកទេស ។ ផ្ទៃដីដែលប៉ះពាល់ដល់ប្រជាពលរដ្ឋ និងផ្ទៃដីព្រៃឈើដែលមានសក្ដានុពលសម្រាប់បរិស្ថាន ត្រូវរក្សាទុកដោយមិនផ្ដល់ឱ្យធ្វើអាជីវកម្មទេ ។ ដីសម្បទានដែលបានផ្ដល់ជូនក្រុមហ៊ុន ត្រូវស្ថិតក្រោមយន្តការតាមដាន ត្រួតពិនិត្យច្បាស់លាស់ ។ កិច្ចសន្យា និងផែនការមេត្រូវប្រើប្រាស់ជាសូចនាករ និងឧបករណ៍សម្រាប់វាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុន ។ កាលពីសប្ដាហ៍កន្លងទៅនេះ ក្រោមយន្តការត្រួតពិនិត្យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងទិសដៅជំរុញការវិនិយោគឱ្យទទួលបានផ្លែផ្កា និងការប្រើប្រាស់ដីសម្បទានឱ្យមានប្រសិទ្ធភាព ក្រុមហ៊ុនចំនួន ៥ ត្រូវរដ្ឋាភិបាលសម្រេចលុបកិច្ចសន្យា និង គោលការណ៍វិនិយោគ មួយចំនួនត្រូវបានតម្រូវឱ្យកែតម្រូវសកម្មភាពអនុវត្ត និងក្រុមហ៊ុន ២ ទៀតត្រូវបានផ្អាកសកម្មភាពដើម្បីធ្វើអធិការកិច្ចបន្ថែម ។ ចំពោះក្រុមហ៊ុនដែលទទួលសម្បទានដីសេដ្ឋកិច្ចមុនច្បាប់ភូមិបាល ហើយមានផ្ទៃដីលើស ១០.០០០ ហ.ត កំពុងស្ថិតក្នុងដំណើរការកាត់បន្ថយឱ្យស្របតាមច្បាប់ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទមានផែនការចរចាបញ្ចប់សម្រាប់ ៥ ក្រុមហ៊ុន ក្នុងឆ្នាំ ២០០៧ ។

ព័ត៌មានពាក់ព័ន្ធដល់សម្បទានដីសេដ្ឋកិច្ចនេះ ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ដែលឯកឧត្តម អស់លោកអាចតាមដានបាន ។ ដូចនេះបង្ហាញឱ្យឃើញសម្បទានដីសេដ្ឋកិច្ចដែលស្ថិតក្រោមយន្តការច្បាស់លាស់ ពិតជារួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រតាមរយៈនៃកំណើនផលិតភាពកសិកម្ម និងការងារសម្រាប់ប្រជាពលរដ្ឋ ។

ចំពោះផ្នែកជលផលវិញត្រូវបានចាត់ជាអនុវិស័យនៃវិស័យកសិកម្ម ដែលមានតួនាទីសំខាន់សម្រាប់ជីវភាពប្រចាំថ្ងៃ ប្រភពចំណូលសម្រាប់ប្រជាពលរដ្ឋ ក៏ដូចជាសម្រាប់ជាតិ និងចាត់ជាធនធានធម្មជាតិដែលមានតម្លៃសម្រាប់កម្ពុជា ។ អនុវិស័យនេះត្រូវបានប្រតិបត្តិទៅតាមបញ្ញត្តិនៃច្បាប់ស្ដីពីជលផល និងលិខិតបទដ្ឋាននានា។ គោលនយោបាយជាតិស្ដីពីជលផលត្រូវអនុម័ត និងផែនការសកម្មភាពតំរោងត្រូវបានអនុវត្ត ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានយកចិត្តទុកដាក់ និងបន្តជំរុញកំណែទម្រង់អនុវិស័យនេះសំដៅ (1) -រក្សាបាននូវនិរន្តរភាពនៃធនធានជលផល (2)- សិទ្ធនៃការប្រើប្រាស់របស់សហគមន៍ត្រូវបានបើកទូលាយ (3)- ចំណូលថវិកាជាតិត្រូវបានបង្កើន ។

សិទ្ធនៃការប្រើប្រាស់ដែននេសាទសាធារណៈរបស់សហគមន៍ ត្រូវបានបើកទូលាយតាមរយៈអនុក្រឹត្យ ស្ដីពីសហគមន៍នេសាទ។ ការរៀបចំគោលការណ៍ណែនាំស្ដីពីសហគមន៍នេសាទត្រូវបានបញ្ចប់ ហើយនឹងដាក់ឱ្យប្រើប្រាស់ក្នុងពេលឆាប់ៗខាងមុខនេះ។ គោលការណ៍នេះនឹងបញ្ចូនក្របខ័ណ្ឌច្បាប់មួយសម្រាប់ធានាដល់ការប្រតិបត្តិរបស់សហគមន៍មានតម្លាភាព គណនេយ្យភាព និង សមធម៌ ក្នុងសហគមន៍ដោយរក្សាបាននូវសុខភាពដែននេសាទ ។

ឡូត៍នេសាទត្រូវបានកែលំអ សំដៅបង្កើនផលស្តុកជលផលសម្រាប់បំរើតម្រូវការប្រជាពលរដ្ឋ និង ចំណូលពីឡូត៍នេសាទត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យតាមប្រព័ន្ធអន្តរក្រសួង ពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនបានពឹងផ្អែកតែលើធនធានធម្មជាតិសម្រាប់បំរើដល់តម្រូវការរបស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចទេ ។ វារីវប្បកម្មត្រូវបានជំរុញខ្លាំងក្លា ។ ការចិញ្ចឹមត្រីក្នុងស្រែ និងចិញ្ចឹមចម្រុះត្រូវបានប្រជាកសិករទទួលយក និងរីកចំរើនគួរជាទីមោទនៈ ។ ទាំងនេះ គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយការធ្វើអាជីវកម្មលើធនធានធម្មជាតិ ។

តម្លៃបន្ថែមនៃផលផលត្រូវបានយកចិត្តទុកដាក់ និងកំពុងជំរុញខ្លាំងក្លា ។ ការកែច្នៃផលនេសាទ គឺជាអាទិភាពក្នុងការរកតម្លៃបន្ថែម ។ ប៉ុន្តែការទទួលស្គាល់គុណភាពផលនេសាទ គឺជាបញ្ហាដែលត្រូវដោះស្រាយ ។ ដូចនេះប្រទេសផ្តល់ជំនួយ ផ្នែកឯកជន ពិសេស សហប្រធានក្រុមការងារជលផលត្រូវទុកបញ្ហានេះចំពោះមុខដែលត្រូវដោះស្រាយរួមគ្នា ។

ចំពោះព្រៃឈើដែលជាធនធានធម្មជាតិសំខាន់ ហើយស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន រដ្ឋាភិបាលបានបង្ហាញអំពីភាពម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងនឹងការបំផ្លាញព្រៃឈើតាមរយៈការដាក់ចេញនូវបទបញ្ជា និងវិធានការដាក់ស្តែងជាបន្តបន្ទាប់ ។ ព្រៃសម្បទានត្រូវបានបន្តផ្អាក ការរំលោភយកដីព្រៃឈើត្រូវបានរដ្ឋាភិបាលធ្វើការរឹបអូសមកវិញតាមរយៈគណៈកម្មការជាតិ និង អនុគណៈកម្មការខេត្ត-ក្រុងដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើកម្មសិទ្ធ ដោយមានកិច្ចសហការពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។ ផ្ទៃដីដែលត្រូវបានរឹបអូសមកវិញត្រូវបានកំពុងចាត់ចែងប្រើប្រាស់ធ្វើការស្តារព្រៃឈើឡើងវិញដែលជាអាទិភាពនៃការប្រើប្រាស់ និង អាទិភាពបន្ទាប់ត្រូវបានពិចារណាប្រើប្រាស់ក្នុងកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច ។

សកម្មភាពនៃបទល្មើសព្រៃឈើត្រូវបានកាត់បន្ថយជាអតិបរមា ។ បទល្មើសព្រៃឈើត្រូវបានប្តូររូបភាពពីទ្រង់ទ្រាយពាណិជ្ជកម្មមកជាទ្រង់ទ្រាយអាជីវកម្មតូច ដោយសារកង្វះការផ្គត់ផ្គង់នៃតម្រូវការក្នុងស្រុក ។ ដំណោះស្រាយបទល្មើសព្រៃឈើត្រូវបានអនុវត្តយ៉ាងប្រុងប្រយ័ត្នទៅតាមគតិច្បាប់ដែលបានកំណត់។ ស្ថាប័នតុលាការត្រូវបានចូលរួមដោះស្រាយដោយមានកិច្ចសហការពីរដ្ឋបាលព្រៃឈើ។ ជនល្មើសត្រូវបានផ្តន្ទាទោសតាមច្បាប់ដោយគ្មានការលើកលែង និង រើសអើង ។ តម្រូវការឈើប្រើប្រាស់ក្នុងស្រុកត្រូវបានពិចារណា និងបានអនុវត្តតាមរយៈការធ្វើអាជីវកម្មព្រៃគុបក្នុងស្រុក ។ សកម្មភាពអាជីវកម្មគុបក្នុងស្រុកត្រូវបានស្ថិតក្រោមការឃ្លាំមើល និងត្រួតពិនិត្យបច្ចេកទេសរបស់មន្ត្រីរដ្ឋបាលព្រៃឈើ។ ម្ចាស់គុបក្នុងស្រុកត្រូវបានព្រមានជាមុនអំពីការអនុវត្តខុសឆ្គងណាមួយ ដែលអាចចាត់ថាជាបទល្មើសព្រៃឈើនឹងត្រូវប្រឈមនឹងច្បាប់ ។

សិទ្ធនៃការប្រើប្រាស់ធនធានព្រៃឈើរបស់សហគមន៍ត្រូវបានធានាដោយច្បាប់ស្តីពីព្រៃឈើ និងត្រូវបានប្រតិបត្តិតាមអនុក្រឹត្យស្តីពី សហគមន៍ព្រៃឈើ ។ ការចងក្រងសហគមន៍កំពុងត្រូវបានជំរុញ សំដៅធានាបាននូវការរស់នៅជាប្រក្រតីរបស់សហគមន៍ និងចូលរួមចំណែកក្នុងការប្រើប្រាស់ និងថែរក្សាព្រៃឈើប្រកបដោយនិរន្តរភាព ។

ការផ្ទៀងផ្ទាត់ទិន្នន័យគំរបព្រៃឈើ ការកំណត់ព្រំប្រទល់ដែនព្រៃឈើ និងការធ្វើសារពើភ័ណ្ឌព្រៃឈើ គឺជាការងារសំខាន់ និងគន្លឹះសម្រាប់ការងារគ្រប់គ្រង និងចាត់ចែងប្រើប្រាស់ព្រៃឈើ និង ដីព្រៃឈើ ។ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ជំរុញធ្វើការផ្ទៀងផ្ទាត់ទិន្នន័យគំរបព្រៃឈើទៅតាមប្រព័ន្ធស្រង់ទិន្នន័យមួយដែលទំនើបជាងប្រព័ន្ធដែលប្រើក្នុងទសវត្សមុនៗ។ ដូចនេះភាពសុក្រឹត្យ និងលំអៀងនៃតួលេខគំរបព្រៃឈើជាបច្ចេកទេសគឺត្រូវតែកើតមាន។ ឯការកំណត់ព្រំប្រទល់ដែនព្រៃឈើ និងសារពើភ័ណ្ឌព្រៃឈើគឺកំពុងតែស្ថិតក្នុងល្បឿនមួយយឺតៗលើកំណាត់ផ្លូវដ៏វែង។ ល្បឿនត្រូវកំណត់ថាជាអនុគមន៍នៃថវិកា បានសេចក្តីថា ថវិកាសម្រាប់ការងារនេះនៅតែជាកត្តាកំណត់ ។ ប៉ុន្តែទោះជាយ៉ាងណាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតែមានសុទិដ្ឋិនិយមថា ប្រទេសផ្តល់ជំនួយក៏យល់ដូចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមិនឈរអោបដៃមើលក្នុងខណៈដែលប្រទេសផ្តល់ជំនួយមានលទ្ធភាពថវិកា និង

មុនផ្តល់គម្រោងជួយដល់អង្គការមួយចំនួនដែលមិនបានរួមចំណែកអនុវត្តផែនការការងារដែលប្រទេសផ្តល់ជំនួយ និង រដ្ឋបាលព្រៃឈើបានរៀបចំតាមរយៈក្រុមការងារនោះទេ ។

សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី

ខ្ញុំយល់ថា សេចក្តីថ្លែងការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើទិដ្ឋភាពរួមនេះ បាក់ដូចជាគ្រប់គ្រាន់សម្រាប់អង្គវេទិកាមើលឃើញអំពីសុឆន្ទៈ និង សកម្មភាពអនុវត្តជាក់ស្តែងរបស់រដ្ឋាភិបាល ទៅតាមកម្មវិធីនយោបាយរបស់ខ្លួនហើយ ។ ឯទិន្នន័យលំអិតក្រុមការងារទាំង ៣ និងលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច អាចផ្តល់ជូនតាមករណីជាក់ស្តែង ។

ខ្ញុំសូមបញ្ចប់សេចក្តីថ្លែងការណ៍របស់ខ្ញុំត្រឹមនេះ ។

សូមអរគុណ